ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គភាពសហមេធាវីនាំមុខ
តំណាងដើមបណ្តឹងរដ្ឋប្បវេណី
Civil Party Lead Co-Lawyers' Section
Section des co-avocats principaux
des parties civiles

កាលបរិច្ឆេទ៖ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៣

លេខយោង: LCLs-2013-00014

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** សំណើសុំសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំគម្រោងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងករណី ០០២

**យោង៖** វិធាន ២៣ *ក្វុនព្វុន* នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីបណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

**តាមរយៈ៖** ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំជាសហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានកិត្តិយសសូមជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី មេត្តាជ្រាបថាយើងខ្ញុំកំពុងរៀបចំគម្រោងសំណងតាមផ្លូវតុលាការនៅក្នុងក្របខណ្ឌនៃសំណុំរឿង ០០២ ដោយសហការជាមួយដៃគូពាក់ព័ន្ធ។

គម្រោងសំណងទាំងនេះមានគោលដៅស្តារកិត្តិយស សេចក្តីថ្លៃថ្នូរ ប៉ះប៉ូវការឈឺចាប់ផ្លូវចិត្ត និងផ្នែកសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រំលឹកដល់អ្នកដែលបានបាត់បង់ជីវិត លើកកំពស់ការយល់ដឹង និងការស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រមទាំងដើម្បីធានាថាបទពិសោធន៍ក្នុងសម័យខ្មែរក្រហមនឹងមិនកើតមានជាថ្មីម្តងទៀតក្នុងសង្គមកម្ពុជា នាពេលអនាគត។

ការទាមទារសំណងគឺជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ វិធានផ្ទៃក្នុងនៃអ.វ.ត.ក (វិធាន ២៣ *ស្ទួនបួន*) បានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងទាមទារសំណងដែលមានលក្ខណៈជាសំណងផ្លូវចិត្ត និងសមូហភាពនៅចំពោះមុខអង្គជំនុំជម្រះជាលើកដំបូងនៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរជាតិ។ សំណងនេះអាចត្រូវបានប្រកាសទទួលស្គាល់ដោយអង្គជំនុំជម្រះកាលណាជនជាប់ចោទម្នាក់ ឬច្រើននាក់ត្រូវបានប្រកាសថាមានទោស។ ការអនុវត្តសំណងត្រូវជាបន្ទុករបស់ទណ្ឌិត ឬ តាមរយៈគម្រោងដែលមានការធានានូវការផ្តល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅដែលផ្តល់ឲ្យដោយអង្គការជាតិ និង/ឬ អន្តរជាតិ និងត្រូវបានត្រៀមរួចជាស្រេច សម្រាប់ការអនុវត្ត។

ចំពោះគម្រោងសំណងណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អាជ្ញាធររាជរដ្ឋាភិបាល អង្គជំនុំជម្រះអាចនឹងផ្តល់ការឯកភាពតែចំពោះគម្រោងណាដែលអាចអនុវត្តបាន ឬ ត្រូវបានរៀបចំរួចជាស្រេច ព្រមទាំងមានការអនុញ្ញាតជាមុនពីអាជ្ញាធររាជរដ្ឋាភិបាល។ ដោយគម្រោងមួយចំនួនពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អាជ្ញាធររាជរដ្ឋាភិបាល យើងខ្ញុំសូមគោរពស្នើសុំ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី មេត្តាផ្តល់ការណែនាំ ឬសេចក្តីសម្រេចចំពោះសំណើដូចខាងក្រោម៖

ក. បង្កើតអនុក្រឹត្យស្តីពីការបង្កើតទិវាជាតិនៃការចងចាំ និង អនុញ្ញាតឲ្យយើងខ្ញុំចូលបំភ្លឺជូនក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវការឲ្យមានការបំភ្លឺបន្ថែមលើខ្លឹមសារដែលស្នើជូន ដូចមាននៅក្នុងឧបសម្ព័ន្ធ ក្នុងចំនុច “ក”។

ខ. ផ្តល់ការណែនាំចាំបាច់នានាដល់អាជ្ញាធរខេត្ត/រាជធានី និងក្រសួងពាក់ព័ន្ធឲ្យធ្វើការសហការជាមួយ អ.វ.ត.ក និងអង្គការពាក់ព័ន្ធផ្សេងៗក្នុងការកំណត់ទីតាំងសម្រាប់ការអភិរក្សអតីតទីតាំងឧក្រិដ្ឋកម្ម ឬវាលពិឃាត ការស្ថាបនាចេតិយ ឬបូជនីយដ្ឋាន ការបង្កើតបណ្ណាល័យ ឬ មណ្ឌលឯកសារតូចៗ និងសារមន្ទីរ ឬការតាំងពិព័ណ៌ ព្រមទាំងចេញសេចក្តីអនុញ្ញាតដល់ការអនុវត្តគម្រោងសំណងលើទីតាំងទាំងនេះ។

គ. ផ្តល់ការណែនាំដល់ចាំបាច់ដល់ក្រសួងអប់រំ យុវជន និងកីឡា ឲ្យបញ្ចូលជាផ្លូវការនូវប្រវត្តិសាស្ត្រខ្មែរក្រហមជាផ្នែកមួយនៃកម្មវិធីសិក្សាជាតិ។

(ព័ត៌មានលំអិតអំពីគម្រោងសំណងនីមួយៗ និងទីតាំងឧក្រិដ្ឋកម្មមានភ្ជាប់ជូនជាឧបសម្ព័ន្ធ)

អាស្រ័យហេតុនេះសូម សម្តេច មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

សូម សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែមិនា ឆ្នាំ២០១៣

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

ពេជ អង្គ

Elisabeth SIMONNEAU FORT

## ឧបសម្ព័ន្ធ៖ សេចក្តីអធិប្បាយលំអិតនៃសំណើសុំ

**ក. ទិវាជាតិនៃការចងចាំ៖** គម្រោងសំណងដែលត្រូវការអនុក្រឹត្យ

ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យមានការកំណត់ជាក់លាក់យកថ្ងៃណាមួយជាទិវាបុណ្យជាតិជាផ្លូវការ ដើម្បីរំលឹកដល់ការឈឺចាប់របស់ជនរងគ្រោះ ព្រមទាំងរំលឹកវិញ្ញាណខ័ន្ធ និងធ្វើបុណ្យឧទ្ទិសដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។ ថ្ងៃនេះគួរផ្តល់ឈ្មោះថា "ទិវាជាតិនៃការចងចាំ" ហើយអាចកំណត់យកថ្ងៃសមស្របណាមួយ។ ក្នុងចំណោមថ្ងៃសក្តានុពល សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើថ្ងៃផ្សេងៗ ដូចជា **ថ្ងៃ២០ ឧសភា ឬ ថ្ងៃ១៧ មេសា ឬ ថ្ងៃ៣០ មិនា ឬ ថ្ងៃសមស្របណាមួយផ្សេងទៀតសម្រាប់ជនរងគ្រោះទាំងអស់**។ វិធានការនេះអាចត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យមួយជា **អនុក្រឹត្យស្តីពីការបង្កើតទិវាជាតិនៃការចងចាំសោកនាដកម្មនៃរបបខ្មែរក្រហម**។

ការស្នើថ្ងៃនីមួយៗមានមូលហេតុដូចខាងក្រោម៖

- ថ្ងៃ២០ ឧសភា៖ ២០ ឧសភា ១៩៧៥ ជាថ្ងៃខ្មែរក្រហមចាប់ផ្តើមផ្សព្វផ្សាយឱ្យអនុវត្តនយោបាយ៨ ចំនុចរបស់ខ្លួន ហើយតាមរយៈនយោបាយនេះ រួមទាំងគោលនយោបាយការជម្លៀសដោយបង្ខំលើកទី ២ និងការដាក់ជាសហករណ៍ផងនោះ មហាវិនាសកម្មដ៏ធំធេងបានកើតមានឡើងនៅកម្ពុជា។ ថ្ងៃនេះត្រូវបានប្រារព្ធឡើងជា "ទិវាចងកំហឹង" ឬជា "ទិវានៃការចងចាំ" តាំងពីឆ្នាំ ១៩៨៤មក។ ថ្ងៃនេះមានអត្ថន័យយ៉ាងទូលំទូលាយយ៉ាងពិតប្រាកដសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងអស់ ព្រោះប្រជាជនស្ទើរតែទូទាំងប្រទេស រួមទាំងប្រជាជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំលើកទី ១ បានឆ្លងកាត់បទពិសោធន៍នៃគោលនយោបាយ៨ ចំណុចរបស់ខ្មែរក្រហម។

- ថ្ងៃ១៧ មេសា៖ ជាថ្ងៃខ្មែរក្រហមវាយឈ្នះទីក្រុងភ្នំពេញ។ វាតំណាងឱ្យការចូលកាន់អំណាចរបស់ខ្មែរក្រហម និងជាថ្ងៃចាប់ផ្តើមជាផ្លូវការនៃរបបមហាវិនាសកម្ម។ ថ្ងៃនេះគឺជាថ្ងៃដែលត្រូវបានស្គាល់យ៉ាងច្រើន ហើយមានអត្ថន័យច្រើនសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលទាមទារអោយមានការទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិ។ ម្យ៉ាងវិញទៀត ថ្ងៃ១៧ មេសានេះគឺផ្សារភ្ជាប់យ៉ាងជិតស្និតទៅនឹងសំណុំរឿង ០០២/០១ ព្រោះវាជាថ្ងៃចាប់ផ្តើមការជម្លៀសដោយបង្ខំលើកទី ១ ហើយវាមានអត្ថន័យទូលំទូលាយសម្រាប់ជនរងគ្រោះទាំងអស់ថាជាការចាប់ផ្តើមនៃការគ្រប់គ្រងប្រទេសដោយខ្មែរក្រហម។

- **ថ្ងៃ៣០ មិនា៖** មានសេចក្តីសម្រេចមួយរបស់គណៈមជ្ឈិម ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦ ដែលមានពាក់ព័ន្ធនឹង "សិទ្ធិសម្រេចកំទេចក្នុងជួរ និងក្រៅជួរ"។ តាមរយៈការអនុវត្តសេចក្តីសម្រេចនេះមានការសម្លាប់ប្រជាពលរដ្ឋជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងនៅក្នុងជួរ និងក្រៅជួរកម្មាភិបាលខ្មែរក្រហម។

២. **ការសហការ និងការកំណត់ទីកន្លែង៖ ១ធានការណ៍ដែលត្រូវការការណែនាំ ឬសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល**

គម្រោងដូចខាងក្រោមនេះអាចអនុវត្តទៅបាន លុះត្រាតែមានការសម្រេច ឬការណែនាំពីរាជរដ្ឋាភិបាល ដើម្បីឲ្យអាជ្ញាធរពាក់ព័ន្ធសហការជាមួយ អ.វ.ត.ក និងអង្គការពាក់ព័ន្ធក្នុងការអនុវត្ត។ គម្រោងទាំងនេះរួមមាន៖

- **ការស្ថាបនាចេតិយ និងបូជនីយដ្ឋាន៖** ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការសាងសង់ចេតិយ ឬបូជនីយដ្ឋាននៅទីតាំងពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបសួរ ដូចមានរៀបរាប់នៅផ្នែកខាងក្រោមនៃឧបសម្ព័ន្ធនេះ ជាពិសេសទីតាំងដែលមានទំនាក់ទំនងនឹងការជម្លៀសដោយបង្ខំទី ១ និងទី ២។ ការស្នើសុំនេះរួមបញ្ចូលទាំងការសាងសង់ស្តូបមួយនៅក្នុងបរិវេណទីធ្លាសារមន្ទីរទួលស្លែងផងដែរ។ ទីកន្លែងដែលស្នើសុំទាំងនេះមានពាក់ព័ន្ធជាអាទិ៍នឹងសមត្ថកិច្ចអាជ្ញាធរខេត្ត និងរាជធានី ដូចជាក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសារទីតាំងដែលនឹងត្រូវសាងសង់ទាំងនេះជាទីតាំងសាធារណៈដែលតម្រូវឲ្យមានគោលការណ៍ណែនាំ ឬសេចក្តីអនុញ្ញាតពីរាជរដ្ឋាភិបាលដើម្បីធានាឲ្យមានកិច្ចសហការក្នុងការអនុវត្តគម្រោងសំណង។

- **ការអភិរក្សអតីតទីតាំងឧក្រិដ្ឋកម្ម ឬវាលពិឃាត៖** ដោយការអភិរក្សទីតាំងឧក្រិដ្ឋកម្ម និងវាលពិឃាតជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត/រាជធានី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យើងខ្ញុំស្នើសុំឲ្យអាជ្ញាធរទាំងនេះសហការផងដែរជាមួយ អ.វ.ត.ក. និងអង្គការពាក់ព័ន្ធក្នុងការកំណត់ទីតាំង និងរក្សាទីតាំងឧក្រិដ្ឋកម្ម ស្របតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ១៣ សរណន ចុះថ្ងៃទី១៤ ធ្នូ ២០០១ ស្តីអំពីការថែរក្សា រៀបចំទុកដាក់អដ្ឋិធាតុប្រជាជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ (១៩៧៥-១៩៧៨) និងការរៀបចំតំបន់អន្លង់វែងឲ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ។ ទីកន្លែងទាំងនេះមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ដែលរួមមានមន្ទីរសន្តិសុខចំនួន ១១ កន្លែង និង

កន្លែងសម្លាប់មនុស្សចំនួន ៤ កន្លែង ព្រមទាំងទីតាំងការដ្ឋាន និងសហករណ៍ ៦ កន្លែង។ (បញ្ជីលំអិតអំពីទីតាំងទាំងនេះមានបញ្ជាក់ជូននៅផ្នែកខាងក្រោមនេះ)។

- **ការបង្កើតបណ្ណាល័យ ឬ មណ្ឌលឯកសារ៖** ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការបង្កើតបណ្ណាល័យ ការបង្កើតមណ្ឌលឯកសារ ឬសារមន្ទីរតូចៗនៅលើទីតាំងសាធារណៈ ឬក្នុងវត្តអារាម ក្នុងស្រុកនីមួយៗយ៉ាងតិចមួយតាមមូលនិធិសម្រាប់អនុវត្តគម្រោងសំណងដែល អ.វ.ត.ក និង/ឬ អង្គការពាក់ព័ន្ធអាចស្វែងរកបាន។ ម្យ៉ាងទៀតបណ្ណាល័យ ឬ មណ្ឌលឯកសារនេះអាចសង់នៅតាមកន្លែងដែលមានការស្ថាបនាចេតិយ ឬបូជនីយដ្ឋានសំរាប់រំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិត និងនៅតាមអតីតទីតាំងឧក្រិដ្ឋកម្ម ឬវាលពិឃាតនានា ដូចមានរៀបរាប់ក្នុងដីកាដំណោះស្រាយ។

ការស្ថាបនាចេតិយ និងបូជនីយដ្ឋាន ការអភិរក្សអតីតទីតាំងឧក្រិដ្ឋកម្ម ឬវាលពិឃាត និងការបង្កើតបណ្ណាល័យ ឬការបង្កើតមណ្ឌលឯកសារតូចៗអាចរៀបចំឡើងនៅកន្លែងជាមួយគ្នា នៅតាមទីតាំងដែលមានរៀបរាប់ក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោមនេះ៖

**<u>ទីតាំងមន្ទីរសន្តិសុខ</u>**

១. មន្ទីរសន្តិសុខ ស ២១ នៅភ្នំពេញ
២. មន្ទីរសន្តិសុខ អូរកន្សែង ស្ថិតនៅក្នុងភូមិ ៦ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគីរី
៣. មន្ទីរសន្តិសុខ កោះខ្យង ស្ថិតក្នុងភូមិកោះខ្យង ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
៤. មន្ទីរសន្តិសុខ គោកក្តួច ស្ថិតក្នុងភូមិកេងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ
៥. មន្ទីរសន្តិសុខ ក្រាំងតាចាន់ ស្ថិតក្នុងឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ
៦. មន្ទីរសន្តិសុខ ភូមិភាគឧត្តរ ស្ថិតក្នុងក្រុងសៀមរាប ខេត្តសៀមរាប
៧. មន្ទីរសន្តិសុខ ព្រៃដំរីស្រុត ស្ថិតក្នុងភូមិច្រាក់សង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
៨. មន្ទីរសន្តិសុខ ភ្នំក្រោល ស្ថិតក្នុងឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី
៩. មន្ទីរសន្តិសុខ សង់ ស្ថិតក្នុងភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
១០. មន្ទីរសន្តិសុខ វត្តគិរីរម្យ ស្ថិតនៅលើភ្នំគិរីរម្យ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង
១១. មន្ទីរសន្តិសុខ វត្តធ្លក ស្ថិតក្នុងភូមិធ្លក ឃុំធ្លក ស្រុកមានជ័យថ្មី (បច្ចុប្បន្ន ស្រុកស្វាយជ្រុំ) ខេត្តស្វាយរៀង

**<u>ទីតាំងកន្លែងសម្លាប់មនុស្ស</u>**

១. កន្លែងសម្លាប់មនុស្ស ជើងឯក ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ

២. កន្លែងសម្លាប់មនុស្ស ស្រុក ១២ ស្ថិតក្នុងភូមិព្រៃត្រពាំងអម្ពិល ភូមិព្រៃត្រពាំងព្រីង និងភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

៣. កន្លែងសម្លាប់មនុស្ស ទួលពោធិ៍ជ្រៃ ស្ថិតក្នុងភូមិក្តីជីវិត ឃុំស្រែដុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់

៤. កន្លែងសម្លាប់មនុស្ស ស្ទឹងតូច ស្ថិតក្នុងភូមិតាហៀវក្រោម ឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម

**<u>ទីតាំងសហករណ៍ និងការដ្ឋាន</u>**

១. ការដ្ឋាន ទំនប់ត្រពាំងថ្ម ស្ថិតក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

២.ការដ្ឋាន ព្រលានយន្តហោះកំពង់ឆ្នាំង ស្ថិតនៅភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

៣. ការដ្ឋាន ស្ទឹងជីនិត ទំនប់ ១ មករា ស្ថិតនៅស្ទឹងជីនិត ស្រុកបារាយណ៍ និងស្រុកសន្ទុក ខេត្តកំពង់ធំ

៤. ការដ្ឋាន ស្រែអំបិល ស្ថិតក្នុងភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកកំពត ខេត្តកំពត

៥. សហករណ៍ ត្រាំកក់ ស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ

៦. មន្ទីរ ស ២៤ ស្ថិតក្នុងភូមិតាឡៃ ឃុំចេក និងបាគូ ខណ្ឌដង្កោ រាជធានីភ្នំពេញ

**គ. វិធានការតម្រូវការឲ្យមានចំណាត់ការរបស់ក្រសួងអប់រំ៖ ការបញ្ចូលជាផ្លូវការនូវប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងកម្មវិធីសិក្សា**

ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំឲ្យមានការបញ្ចូលជាផ្លូវការនូវប្រវត្តិសាស្ត្រនេះក្នុងកម្មវិធីសិក្សាជាតិ យ៉ាងតិចនៅថ្នាក់ចំណេះដឹងទូទៅ ពីថ្នាក់ទី ៧ ដល់ទី ១២ ទាំងនៅសាលារដ្ឋ និងសាលាឯកជន និងនៅថ្នាក់មូលដ្ឋាននៃកម្មវិធីសិក្សាថ្នាក់ឧត្តមសិក្សា។ ការសិក្សានេះមានគោលបំណងឲ្យសិស្ស/និស្សិតយល់ដឹងឲ្យបានជាក់លាក់អំពីសោកនាដកម្មដែលបានកើតឡើង និងរួមគ្នាផ្សព្វផ្សាយព្រមទាំងទប់ស្កាត់ដើម្បីកុំឲ្យមានអំពើឃោរឃៅបែបនេះកើតមានឡើងជាថ្មីក្នុងសង្គមកម្ពុជា។